# ឃដបណ្ឌិតជាតក



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង**

**ព.ស. ២៥៦៤**

# ឃដបណ្ឌិតជាតក

រៀបរៀងដោយ

បណ្ឌិត **កុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| *ឈ្មោះសៀវភៅ* | **យវបណ្ឌិតជាតក** |
| *រៀបរៀងដោយ* | *បណ្ឌិត* **ភុល ផេង** |
| | *ប្រធានពុទ្ធិកបណ្ឌិតសភា* |
| | *នៃសាកលវិទ្យាល័យ* |
| | *បញ្ញាសាស្ត្រកម្ពុជា* |
| *ទីតាំងធ្វើ* | *ពុទ្ធិកបណ្ឌិតសភា* |
| *ការផ្សាយ* | *របស់ពុទ្ធិកបណ្ឌិតសភា* |
| *រក្សាសិទ្ធិ* | *ពុទ្ធិកបណ្ឌិតសភា* |
| *កាលបរិច្ឆេទ* | *ថ្ងៃអង្គារ ២ រោច ខែ* |
| | *អាសាឍ ឆ្នាំជូត ទោស័ក* |
| | *ព.ស. ២៥៦៤* |
| | *ថ្ងៃទី ៧ ខែ កក្កដា គ.ស.* |
| | *២០២០* |

# **យវបណ្ឌិតជាតក**

## **បុព្វនិទាន**

*ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈ ដែលមានកូនស្លាប់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឧជ្ជេហិ កាណ្ហា** *ដូច្នេះជាដើម ។*

## **បច្ចុប្បន្ននិទាន**

*រឿងបច្ចុប្បន្ន ប្រាកដដូចរឿងក្នុង* ***មដ្ឋកុណ្ឌលិ-ជាតក*** *។ ចំណែកក្នុងជាតកនេះ ព្រះសាស្ដាត្រាស់នឹងឧបាសកនោះថា ម្នាលឧបាសក អ្នកសោយសោកឬ? កាលឧបាសកពោលថា ពិតមែន ព្រះអង្គ, ព្រះសាស្ដាទើបត្រាស់ថា ម្នាលឧបាសក បោរាណកបណ្ឌិតទាំងឡាយបានស្ដាប់កថារបស់បណ្ឌិតទាំងឡាយហើយ ក៏លែងសោយសោកនឹងកូនដែលស្លាប់ ដូច្នេះ*

*ហើយ កាលឧបាសកអារាធនាហើយ ទ្រង់នាំយក អតីតនិទានមកសម្ដែងថា*

**អតីតនិទាន**

*ក្នុងអតីតកាល ព្រះរាជាព្រះនាម **មហាកំសៈ** សោយរាជសម្បត្តិ ក្នុង**អសិតញ្ជននគរ** ក្នុងដែន**កំស-ភោគៈ** ក្នុង**ឧត្តរបថជនបទ** ។ ព្រះបាទមហាកំសៈនោះ មានមានព្រះឱរស ២ អង្គ គឺ **កំសៈ** ១ **ឧបកំសៈ** ១ និង មានព្រះធីតា ១ អង្គ ឈ្មោះ **ទេវគព្ភា** ។ ក្នុងថ្ងៃដែល ព្រះរាជធីតាប្រសូត ព្រាហ្មណ៍អ្នកទាយនិមិត្តព្យាករ ថា បុត្រដែលកើតក្នុងផ្ទៃរបស់ព្រះនាង នឹងញុំាង**កំស-គោត្ត**និង**កំសវង្ស**ឲ្យវិនាស ។ ដោយសេចក្ដីស្រឡាញ់ ព្រះរាជធីតាដ៏ខ្លាំង ព្រះរាជាមិនអាចដើម្បីនឹងញុំាង ព្រះរាជធីតាឲ្យវិនាសឡើយ, សូម្បីព្រះភាតរៈក៏ទ្រង់ ជ្រាបដោយប្រការនេះដែរ ព្រះរាជាតម្កល់ទុករហូត*

*ដល់ទ្រង់អស់ព្រះជន្ម ស្ដេចសោយទិវង្គតទៅ ។ កាលព្រះរាជាធ្វើសោយទិវង្គតទៅហើយ **កំសកុមារ**ក៏បានជាព្រះរាជា, **ឧបកំសៈ**បានជាឧបរាជ ។ ព្រះរាជានិងឧបរាជគិតគ្នាថា ប្រសិនបើយើងនឹងញ៉ាំងប្អូនស្រីឲ្យវិនាស, យើងនឹងត្រូវគេតិះដៀល, ដូច្នេះយើងនឹងមិនឲ្យនាងដល់អ្នកណាឡើយ ធ្វើនាងមិនឲ្យមានស្វាមី ពួកយើងនឹងចិញ្ចឹមនាង ។ ព្រះរាជានិងឧបរាជឲ្យគេកសាងប្រាសាទសសរមួយ ឲ្យព្រះនាងទេវគព្ភារស់នៅលើប្រាសាទនោះ, ឲ្យស្រីឈ្មោះ **នន្ទិគោបា** ជាអ្នកបម្រើព្រះនាង, ឲ្យទាសៈ ឈ្មោះ **អន្ធកវេណ្ឌុ**ៈដែលជាស្វាមីរបស់នាងនន្ទិគោបានោះធ្វើការរក្សាការពារ ។*

*ក្នុងគ្រានោះដែរ ព្រះរាជាព្រះនាម **មហាសាគរ** សោយរាជសម្បត្តិក្នុង**ឧត្តរមធុរានគរ** ។ ព្រះបាទមហា-សាគរមានព្រះឱរស ២ អង្គគឺ **សាគរ** ១ **ឧបសាគរ** ១ ។*

កាលដែលបិតាកន្លងផុតទៅ សាគររាជបុត្របានជាព្រះរាជា, ឧបសាគរបានជាឧបរាជ ។ ឧបសាគរនោះជាមិត្រដែលសិក្សាសិល្បៈជាមួយ ក្នុងត្រកូលជាអាចារ្យតែមួយជាមួយនឹងឧបកំសៈ ។ ឧបសាគរប្រទូស្តស្ត្រីក្នុងរាជបុរីរបស់ព្រះភាតុម្ចាស់បងសាគរ, កាលភ័យខ្លាច ក៏រត់ចេញ ទៅកាន់សម្នាក់ឧបកំសៈក្នុងដែនកំសភោគៈ ។ ឧបកំសៈនាំឧបសាគរទៅថ្វាយព្រះរាជា, ព្រះរាជាប្រទានយសដ៏ធំឲ្យឧបសាគរនោះ ។ ឧបសាគរកាលទៅកាន់ទីបម្រើព្រះរាជា បានឃើញប្រាសាទសសរមួយដែលជានិវាសរបស់ព្រះនាងទេវគព្ភា ហើយសួរគេថា "នោះជានិវាសរបស់អ្នកណា" បានស្តាប់ហេតុការណ៍នោះហើយ ក៏មានចិត្តប្រតិព័ទ្ធព្រះនាងទេវគព្ភា ។ ថ្ងៃមួយ សូម្បីព្រះនាងទេវគព្ភាក៏បានឃើញឧបសាគរដែលមកកាន់ទីបម្រើព្រះរាជា

ជាមួយនឹងឧបកំសៈ ហើយសួរអ្នកបម្រើថា នោះជាអ្នកណា ? បានស្ដាប់អំពីសម្នាក់នាងនន្ទិគោបាថា ជារាជបុត្ររបស់ព្រះបាទមហាសាគរ ព្រះនាមឧបសាគរ ដូច្នេះហើយ ព្រះនាងក៏មានចិត្តប្រតិព័ទ្ធនឹងឧបសាគរនោះ ។ ឧបសាគរឲ្យសំណូកដល់នាងនន្ទិគោបាពោលថា នែប្អូនស្រី អាចនាំយើងឲ្យទៅជួបនាងទេវ-គព្ភាបានទេ ។ នាងនន្ទិគោបាពោលថា បពិត្រព្រះអង្គម្ចាស់ មិនអាចទេ ជាកម្មធ្ងន់ណាស់ ដូច្នេះហើយ នាងទៅប្រាប់ហេតុការណ៍នោះ ដល់នាងទេវគព្ភា ។ ដោយប្រក្រតី ព្រះនាងក៏មានចិត្តប្រតិព័ទ្ធឧបសាគរស្រាប់ហើយ ទើបព្រះនាងទទួលថា ប្រពៃហើយ ។ នាងនន្ទិគោបាឲ្យសញ្ញាដល់ឧបសាគរ ប្រាប់ឲ្យឡើងកាន់ប្រាសាទនោះ ក្នុងពេលរាត្រី ។ ឧបសាគរក៏បានសម្រេចសំវាសជាមួយនឹងព្រះនាងទេវគព្ភា ។ បន្ទាប់

មក ដោយការប្រព្រឹត្តសំវាសរឿយៗ ព្រះនាងទេវគព្ភា
ក៏មានគភ៌ ។

ខាងក្រោយមក គភ៌របស់ព្រះនាងប្រាកដឡើង ។
ព្រះភាតរៈសួរនាងនន្ទិគោបា, នាងនន្ទិគោបាសូម
អភ័យទោស រួចប្រាប់រឿងនោះ ។ ព្រះរាជាស្តាប់
ហើយ ទ្រង់គិតថា យើងមិនអាចឲ្យប្អូនស្រីវិនាស
ឡើយ, បើនឹងកើតកូនស្រី យើងនឹងមិនធ្វើឲ្យវិនាសទេ
បើនឹងជាកូនប្រុស យើងនឹងឲ្យវាវិនាស ដូច្នេះហើយ
ទ្រង់ក៏ប្រទាននាងទេវគព្ភាដល់ឧបសាគរ ។ នាងទេវ-
គព្ភាប្រសូតបានកូនស្រី ។ ព្រះភាតរៈស្តាប់ហើយ
មានចិត្តត្រេកអរ ហើយដាក់ឈ្មោះឲ្យថា **អញ្ជនទេវី** ។
ព្រះរាជាទ្រង់ប្រទាន**ភោគគ្រាម**ដែលមានឈ្មោះថា
**ភោគវឌ្ឍមានៈ**ដល់ឧបសាគរនិងនាងទេវគព្ភានោះ ។
ឧបសាគរនាំនាងទេវគព្ភាទៅរស់នៅក្នុង**ភោគវឌ្ឍមាន-**

គ្រាម ។ គភ៌ក៏តាំងឡើងដល់ព្រះនាងទេវគព្ភាទៀត, សូម្បីនាងនន្ទិគោបាក៏មានគភ៌ក្នុងថ្ងៃនោះដែរ ។ កាលគភ៌បរិបូណ៌គ្រប់ខែហើយ ក្នុងថ្ងៃតែមួយនោះ ព្រះនាងទេវគព្ភាកើតបានកូនប្រុស, នាងនន្ទិគោបាកើតបានកូនស្រី ។ ដោយសេចក្ដីភ័យខ្លាចកូនវិនាស ព្រះនាងទេវគព្ភាបានបញ្ជូនកូនប្រុសទៅឲ្យនាងនន្ទិគោបាដោយរហ័ស និងឲ្យនាំកូនស្រីរបស់នាងនន្ទិគោបាមកវិញ ។ អាមាត្យទាំងឡាយក្រាបទូលដំណឹងការប្រសូតបុត្ររបស់ព្រះនាងដល់ព្រះភាតរៈ ។ ព្រះភាតរៈសួរថា ជាកូនប្រុស ឬ កូនស្រី ? កាលអាមាត្យទូលថា ជាកូនស្រី, ទ្រង់ត្រាស់ថា បើយ៉ាងនោះ ចូរចិញ្ចឹមចុះ ។ ដោយឧបាយនោះ ព្រះនាងទេវគព្ភាក៏កើតបានកូនប្រុស ១០, នាងនន្ទិគោបាកើតបានកូនស្រី ១០ ។ បុត្រទាំង ១០ ចម្រើនវ័យធំឡើងក្នុងសម្នាក់នាងនន្ទិគោបា,

*ចំណែកកូនស្រីចម្រើនវ័យធំឡើងក្នុងសម្នាក់ព្រះនាងទេវគព្ភា ។ មិនមានអ្នកណាដឹងរឿងសម្ងាត់នោះឡើយ ។ បុត្រច្បងរបស់ព្រះនាងទេវគព្ភាមានឈ្មោះថា* ***វាសុទេព****, ទី ២ ឈ្មោះថា* ***ពលទេព****, ទី ៣ ឈ្មោះថា* ***ចន្ទទេព****, ទី ៤ ឈ្មោះថា* ***សូរិយទេព****, ទី ៥ ឈ្មោះថា* ***អគ្គិទេព****, ទី ៦ ឈ្មោះថា* ***វរុណទេព****, ទី ៧ ឈ្មោះថា* ***អជ្ជុនៈ****, ទី ៨ ឈ្មោះថា* ***បជ្ជុនៈ****, ទី ៩ ឈ្មោះ* ***ឃដបណ្ឌិត****, ទី ១០ ឈ្មោះថា* ***អង្កុរៈ*** *។ បងប្អូនប្រុសទាំង ១០ ក៏បានប្រាកដថា ជាកូនរបស់អន្ធកវេណ្ហុៈនិងជាបាវព្រាវ ។*

*ខាងក្រោយមក កាលបុត្រទាំងនោះចម្រើនធំហើយ ជាអ្នកមានកម្លាំងខ្លាំង ជាមនុស្សកាចសាហាវអាក្រក់ នាំគ្នាត្រាច់ឆក់ប្លន់អ្នកស្រុក, សូម្បីបណ្ណាការដែលគេបញ្ជូនទៅថ្វាយព្រះរាជា ក៏នាំគ្នាប្លន់ដែរ ។*

មនុស្សទាំងឡាយប្រជុំគ្នា ពោលទោលត្រង់ព្រះលាន
ហ្លួងថា បងប្អូនប្រុសទាំង ១០ ជាកូនរបស់ទាសៈអន្ធក-
វេណ្ហៈបួន់រដ្ឋហើយ ។ ព្រះរាជាត្រាស់ឲ្យហៅអន្ធក-
វេណ្ហៈចូលគាល់ ហើយសម្តុតគំរាមថា ព្រោះហេតុអ្វី
ទើបអ្នកឲ្យកូនទៅធ្វើការប្ងន់ដូច្នេះ ។ មនុស្ស
ទាំងឡាយនាំគ្នាពោលទោសសូម្បីលើកទី ២ សូម្បី
លើកទី ៣ ព្រះរាជាក៏គំរាមគេទៀត ។ នាយអន្ធក-
វេណ្ហៈភ័យខ្លាចស្លាប់ សូមព្រះរាជាអភ័យទោស រួច
ប្រាប់រឿងសម្ងាត់នោះថា បពិត្រព្រះសម្មតិទេព ក្មេង
ទាំងនោះ មិនមែនជាកូនរបស់ទូលបង្គំទេ គឺជាបុត្រ
របស់ឧបសាគរ ។ ព្រះរាជាទ្រង់ភ័យខ្លាច ត្រាស់សួរ
ពួកអាមាត្យថា យើងនឹងចាប់ពួកវាដោយឧបាយដូច
ម្តេច ? ពួកអាមាត្យទូលថា បពិត្រព្រះសម្មតិទេព
ក្មេងទាំងនោះចូលចិត្តចំបាប់ប្រយុទ្ធគ្នា ទូលបង្គំនឹង

រៀបចំការប្រកួតក្នុងនគរ កាលក្មេងទាំងនោះមកកាន់ **យុទ្ធមណ្ឌល** ពួកយើងនឹងចាប់វា ហើយសម្លាប់ចោលនៅក្នុងទីនោះតែម្តង ដូច្នេះហើយ ទ្រង់បញ្ជូនអ្នកចំបាប់ ២ នាក់ គឺ **ចារុរៈ ១ មុដ្ឋិកៈ ១** និងឲ្យត្រាច់វាយស្គរប្រកាសក្នុងនគរថា ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ នឹងមានការប្រកួត ដូច្នេះហើយ ទ្រង់ឲ្យគេរៀបចំយុទ្ធមណ្ឌលត្រង់ព្រះលានហ្លួង ឲ្យធ្វើសង្វៀន ឲ្យតាក់តែងយុទ្ធមណ្ឌល ឲ្យចងទង់បដា ។ ដំណឹងនោះបានផ្សាយទៅពេញនគរ ។ មនុស្សទាំងឡាយចងតម្រួតចក្រលើចក្រ តម្រួតគ្រែលើគ្រែ ។ ចារុរៈនិងមុដ្ឋិកៈ មកកាន់យុទ្ធមណ្ឌល ស្រែកគំរាមកំហែង បញ្ចេញក្បាច់គុនត្រាច់ទៅ ។ ចំណែកបងប្អូនប្រុសទាំង ១០ មកបណ្តើរ ប្លន់អាហារតាមផ្លូវបណ្តើរ ស្ទៀកសំពត់ពណ៌ប្លន់គ្រឿងក្រអូបក្នុងផ្សារ, ប្លន់កម្រងផ្កាក្នុងផ្សាររបស់

មាលាការ, ទ្រទ្រង់កម្រងផ្កា ប្រដាប់នៅនឹងត្រចៀក
ស្រែកគំរាម បញ្ចេញក្បាច់គុន ចូលទៅកាន់យុទ្ធ-
មណ្ឌល ។ ខណៈនោះ ចារុរៈត្រាច់លើកដៃ ។ ពល-
ទេពឃើញចារុរៈនោះហើយ គិតថា យើងមិនបាច់ប៉ះ
អាគាត់នេះដោយដៃទេ គិតហើយ ក៏ទៅយកខ្សែចង
ដំរីដ៏ធំអំពីរោងដំរី ស្រែកគំរាម បោះខ្សែរុំព័ទ្ធចារុរៈ
ត្រង់ពោះ ធ្វើចុងខ្សែឲ្យនៅចំណែកតែមួយ ហើយ
លើកគ្រវីនៅលើក្បាល រួចបោកលើដី ហើយបោះទៅ
ក្រោសង្វៀន ។ កាលចារុរៈស្លាប់ហើយ ព្រះរាជាបញ្ជា
ឲ្យអ្នកចំបាប់ឈ្មោះ មុដ្ឋិកៈ ចូល ។ មុដ្ឋិកៈក្រោកឡើង
ស្រែកគំរាម ចូលទៅ ។ ពលទេពវាយមុដ្ឋិកៈ ធ្វើឆ្អឹងឲ្យ
បាក់ខ្ទេច កាលមុដ្ឋិកៈពោលថា ខ្ញុំមិនមែនអ្នកចំបាប់
ទេ ខ្ញុំមិនមែនអ្នកចំបាប់ទេ ដូច្នេះ ពលទេពពោលថា
យើងមិនដឹងភាពជាអ្នកចំបាប់ ឬមិនមែនជាអ្នកចំបាប់

របស់អ្នកទេ ថារួចចាប់ដៃ បោកទៅលើដី ធ្វើអស់ជីវិត រួចបោះទៅខាងក្រៅសង្វៀន ។ មុដ្ឋិកៈកាលស្លាប់បាន តាំងសេចក្តីប្រាថ្នាថា បើយើងកើតជាយក្ស យើងនឹង ស៊ីពលទេពនេះ ។ មុដ្ឋិកៈនោះកើតជាយក្ស ឈ្មោះ **កាលមត្តិកៈ** ក្នុងព្រៃមួយ ។ ព្រះបាទកំសៈក្រោកឡើង បញ្ជាថា អ្នកទាំងឡាយចូរចាប់បងប្អូនប្រុសដែលជា បាវព្រាវទាំង ១០ នាក់ ។ ខណៈនោះ វាសុទេពគ្រវែង ចក្រទៅ ។ ចក្រនោះហោះទៅកាត់សីសៈរបស់ ព្រះបាទកំសៈ និងឧបកំសៈទាំងពីរនាក់ឲ្យដាច់ធ្លាក់ ចុះ ។ មហាជនភ័យខ្លាច ពោលថា សូមលោកជាពឹង របស់យើង ថារួចនាំគ្នាក្រាបទៀបជើងរបស់បងប្អូន ទាំងនោះ ។ បងប្អូនទាំង ១០ នោះសម្លាប់អ៊ំប្រុស ហើយ កាន់យករាជសម្បត្តិក្នុងអសិតញ្ជននគរហើយ ឲ្យមាតាបិតាឲ្យនៅរស់នៅទីនោះ ពោលថា ពួកយើង

*នឹងកាន់យករាជសម្បត្តិក្នុងសកលជម្ពូទ្វីប ថាហើយក៏ចេញ ទៅកាន់**អយុជ្ឈនគរ** ដែលជានិវាសរបស់ព្រះបាទ**កាលយោនកៈ** ឡោមព័ទ្ធនគរនោះ វាយកម្ទេចព្រៃជាខ្នងក្រុង ទម្លាយកំពែង ទៅចាប់ព្រះរាជាធ្វើរាជសម្បត្តិឲ្យតាំងនៅក្នុងកណ្តាប់ដៃខ្លួនហើយ (ធ្វើយ៉ាងនេះ) តាមលំដាប់ រហូតដល់**នគរទ្វារវតី** ។ នគរទ្វារវតីនោះ មានសមុទ្រតាំងនៅមួយចំណែក មានភ្នំតាំងនៅមួយចំណែក បានឮមកថា នគរទ្វារវតីនោះមានអមនុស្សរក្សា ។*

*យក្សដែលរក្សានគរនោះ ពេលឃើញបច្ចាមិត្តហើយ ក្លែងភេទជាលា ហើយស្រែកសំឡេងលា ។ ក្នុងខណៈនោះ ដោយអានុភាពនៃយក្ស នគរទាំងមូល ក៏អណ្តែតហោះឡើង ទៅតាំងនៅលើកោះក្នុងមហាសមុទ្រ ។ កាលដែលសត្រូវទាំងឡាយទៅហើយ ទើប*

នគរនោះអណ្តែតមកកាន់កន្លែងដើមរបស់ខ្លួនវិញ ។ សូម្បីគ្រានោះ សត្វលានោះដឹងនូវការមកនៃស្តេចជាបងប្អូនទាំង ១០ នាក់ ទើបស្រែកសំឡេងលាឡើង ។ នគរក៏អណ្តែតទៅឋិតនៅលើកោះ ស្តេចទាំងនោះមិនឃើញនគរ កាលនាំគ្នាត្រឡប់ទៅវិញហើយ នគរទើបមកឋិតនៅលើស្ថានទីរបស់ខ្លួនវិញ ។ ស្តេចទាំង ១០ អង្គត្រឡប់មកម្តងទៀត សត្វលាក៏ធ្វើយ៉ាងនោះទៀតដែរ ។ ស្តេចទាំង ១០ អង្គនោះកាលមិនអាចនឹងរឹបយករាជសម្បត្តិក្នុងនគរទ្វារវតីបាន ទើបទៅកាន់សម្នាក់**កណ្ហទីបាយនឥសី** ថ្វាយបង្គំ ហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងខ្ញុំមិនអាចរឹបយករាជសម្បត្តិក្នុងនគរទ្វារវតីបាន សូមលោកម្ចាស់ធ្វើឧបាយមួយដល់យើងខ្ញុំផង ។ កាលឥសីប្រាប់ថា មានសត្វលាមួយនៅក្នុងទីឯណោះ ជាទីដែលគេ

ដីកដោយជុំវិញក្នុងខាងក្រៅនៃក្រុង ។ សត្វលានោះ ពេលឃើញសត្រូវហើយស្រែកឡើង, ក្នុងខណៈនោះ នគរក៏អណ្តែតទៅ, អ្នកទាំងឡាយចូរចាប់ជើងលា នោះ, នេះជាឧបាយដែលឲ្យអ្នកទាំងឡាយសម្រេច បាន ។ ស្ដេចទាំង ១០ អង្គថ្វាយបង្គំតាបស ហើយទៅ ចាប់ជើងសត្វលានោះ ហើយក្រាបចុះ និងសូមអង្វរថា បពិត្រលោកម្ចាស់ដ៏ចម្រើន វៀរចាកលោកម្ចាស់ចេញ ហើយ បុគ្គលដទៃដែលជាទីពឹងរបស់យើងខ្ញុំ រមែង មិនមាន, កាលដែលពួកខ្ញុំរឹបយកនគរ សូមលោកកុំ ស្រែក ។ សត្វលាពោលថា យើងមិនអាចមិនស្រែក បានទេ, តែថាពួកលោក ៤ នាក់ចូរមកមុន ចូរកាន់ យកនង្គ័លដែកធំ ហើយដំបង្គោលដែកធំនឹងផែនដី ត្រង់ទ្វារនគរទាំង ៤ កាលនគរអណ្តែតឡើង ចូរចាប់

នង្គ័ល ជួយគ្នាយកច្រវាក់ដែកចងនង្គ័លភ្ជាប់នឹង
បង្គោលដែក នគរនឹងមិនអាចអណ្តែតទៅបានឡើយ ។

ស្តេចទាំងនោះពោលថា ប្រពៃហើយ ។ កាល
ដែលសត្វលាមិនទាន់ស្រែក ស្តេចទាំងនោះកាន់យក
នង្គ័ល ដំបង្គោលនឹងផែនដីត្រង់ទ្វារនគរទាំង ៤ ។
ខណៈនោះ សត្វលាស្រែកឡើង, នគរប្រារព្ធនឹង
អណ្តែត ។ មនុស្សទាំងឡាយដែលឋិតនៅត្រង់ទ្វារ
ទាំង ៤ ចាប់នង្គ័លដែកទាំង ៤ យកច្រវាក់ដែកចង
នង្គ័លនឹងបង្គោល, នគរមិនអាចអណ្តែតឡើង ។
លំដាប់នោះ ស្តេចបងប្អូនប្រុសទាំង ១០ អង្គចូលកាន់
នគរ សម្លាប់ព្រះរាជាទាំងឡាយ ហើយរឹបយករាជ-
សម្បត្តិ ។ ស្តេចបងប្អូនប្រុសទាំង ១០ អង្គនោះញុំាង
ព្រះរាជាទាំងអស់ ក្នុងនគរ ៦៣,០០០ ក្នុងសកល-
ជម្ពូទ្វីប ឲ្យដល់ការអស់ជីវិតដោយប្រើចក្រ, កាលរស់

នៅក្នុងនគរទ្វារវតីនោះ បានបែងចែករាជសម្បត្តិជា ១០ ចំណែក, ដោយមិនបានរលឹកដល់បងស្រីអញ្ជន-ទេវី ។ បន្ទាប់មក នឹកឃើញ ទើបពោលថា ពួកយើងនឹងធ្វើរាជសម្បត្តិឲ្យជា ១១ ចំណែក ។ ពេលនោះ អង្កុរៈ (ដែលជាប្អូនពៅ) ពោលថា អ្នកទាំងឡាយចូរឲ្យចំណែករបស់ខ្ញុំដល់ព្រះនាងចុះ ខ្ញុំនឹងធ្វើជំនួញចិញ្ចឹមជីវិត តែអ្នកទាំងឡាយចូរលះបង់សួយក្នុងជនបទរបស់ខ្លួនដល់ខ្ញុំ ។ ស្តេចទាំងនោះទទួលថា ប្រពៃហើយ រួចឲ្យចំណែករបស់អង្កុរៈដល់បងស្រី, ព្រះរាជាទាំង ៩ អង្គមួយអន្លើដោយបងស្រី រស់នៅក្នុងនគរទ្វារវតី ។ ចំណែកអង្កុរៈធ្វើពាណិជ្ជកម្ម ។ កាលព្រះរាជាទាំងឡាយនោះចម្រើនដោយបុត្រធីតាបន្តបន្ទាប់មកយ៉ាងនេះ ព្រះរាជមាតាបិតា ក៏ធ្វើកាល-កិរិយាទៅ ។

គ្រានោះ បានឮមកថា ជាកាលដែលមនុស្សមាន អាយុ ២០,០០០ ឆ្នាំ ។ ក្នុងពេលមួយនោះ បុត្រ វាសុទេពមហារាជធ្វើកាលកិរិយា ។ ព្រោះសេចក្ដី សោកនឹងបុត្រស្លាប់ ព្រះរាជាលះបង់កិច្ចទាំងពួង កាន់យកធ្នឹង យំសោយសោក ផ្ទំលើគ្រែ ។ ពេលនោះ យវបណ្ឌិតគិតថា វៀរចាកយើងហើយ អ្នកដទៃណា មួយ ឈ្មោះថា អាចដើម្បីនឹងនាំសេចក្ដីសោក របស់ បងប្រុសរបស់យើង រមែងមិនមាន, យើងនឹងនាំចេញ នូវសេចក្ដីសោកដោយឧបាយ ។ យវបណ្ឌិតនោះ កាន់យកភេទជាមនុស្សឆ្កួត ពោលថា អ្នកចូរឲ្យ ទន្សាយដល់ខ្ញុំ អ្នកចូរឲ្យទន្សាយដល់ខ្ញុំ ដូច្នេះហើយ សម្លឹងមើលអាកាស ត្រាច់ទៅពេញសកលនគរ ។ ដំណឹងថា យវបណ្ឌិតជាមនុស្សឆ្កួត ដូច្នេះបានផ្សាយ ទៅពេញនគរ ។ ក្នុងកាលនោះ អាមាត្យឈ្មោះ

*រោហិណេយ្យៈ ទៅកាន់សម្នាក់ព្រះបាទវាសុទេព កាលញ៉ាំងកថាជាមួយនឹងព្រះអង្គឲ្យតាំងឡើង ទើបពោលគាថាទី ១ ថា*

ឧដ្ឋេហិ កណ្ហ កឹ សេសិ,
កោ អត្ថោ សុបនេន តេ;
យោបិ តុយ្ហំ សកោ ភាតា,
ហទយំ ចក្ខុ ច ទក្ខិណំ;
តស្ស វាតា ពលីយន្តិ,
ឃដោ ជប្បតិ កេសវ។

*បពិត្រព្រះអង្គ ជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង ព្រះអង្គនៅផ្ទំធ្វើអ្វី ប្រយោជន៍អ្វីរបស់ព្រះអង្គដោយការផ្ទំ ក្សត្រិយ៍ណា ជាព្រះកនិដ្ឋភាតារបស់ខ្លួនព្រះអង្គ ( ស្មើដោយ ) ហឫទ័យ និងព្រះនេត្រខាងស្តាំ ខ្យល់ចាប់រួមរឹតនូវហឫទ័យរបស់*

ក្សត្រិយ៍ ជាព្រះកនិដ្ឋភាតានោះ បពិត្រព្រះកេសវៈ យវបណ្ឌិត រមែងអំពាវនាវថា (អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង ) ។

កាលអាមាត្យទូលយ៉ាងនេះហើយ ទ្រង់ដឹងនូវភាពឆ្លូតរបស់យវបណ្ឌិត ។

ព្រះសាស្តាជាអភិសម្ពុទ្ធទ្រង់ត្រាស់គាថាទី ២ ថា

តស្ស តំ វចនំ សុត្វា,
រោហិណេយ្យស្ស កេសវោ;
តរមានរូបោ វុដ្ឋាសិ,
ភាតុសោកេន អដ្ដិតោ។

ព្រះបាទកេសវៈទ្រង់ព្រះសណ្តាប់ពាក្យ របស់អាមាត្យឈ្មោះរោហិណេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើង រលះរលាំង ត្រូវសេចក្តីសោកក្នុងព្រះកនិដ្ឋភាតាគ្របសង្កត់ ។

ព្រះរាជាក្រោកឡើង ចុះចាកប្រាសាទដោយប្រញាប់ យាងទៅកាន់សម្នាក់យវបណ្ឌិត ហើយចាប់ដៃទាំងពីរយ៉ាងមាំ កាលនឹងចរចាជាមួយនឹងយវបណ្ឌិត ទើបត្រាស់គាថាទី ៣ ថា

**កិំ នុ ឧម្មត្តរូបោវ,**
**គោវលំ ទ្វារកំ ឥមំ;**
**សសោ សសោតិ លបសិ,**
**កោ នុ តេ សសមាហរិ។**

អ្នកហេតុអ្វី ក៏មានសភាពហាក់ដូចជាឆ្កួត (ត្រាច់ទៅ) កាន់នគរទ្វារវតីទាំងមូលនេះ និយាយរវើរវាយថា ទន្សាយ ៗ អ្នកណាលួចយកទន្សាយ របស់អ្នកទៅឬ ។

កាលព្រះរាជាត្រាស់ដូច្នេះហើយ យវបណ្ឌិតពោលនូវពាក្យនោះដដែលរឿយៗ ។ ព្រះរាជាត្រាស់ ២ គាថាទៀតថា

សោវណ្ណមយំ មណីមយំ,
លោហមយំ អថ រូបិយាមយំ;
សង្ខសិលាបវាឡមយំ,
ការយិស្សាមិ តេ សសំ។

សន្តិ អញ្ញេបិ សសកា,
អរញ្ញេ វនគោចរា;
តេបិ តេ អានយិស្សាមិ,
កីទិសំ សសមិច្ឆសិ។

*អ្នកប្រាថ្នានូវទន្សាយមាស កែវមណី ឬប្រាក់ ឬក៏ទន្សាយធ្វើដោយស័ង្ខ ដោយសិលា ដោយកែវប្រពាល យើងនឹងឲ្យគេធ្វើទន្សាយនោះ ដល់អ្នក ។*

*( បើអ្នកមិនពេញចិត្តទន្សាយនោះទេ ) ទន្សាយឯទៀតក្នុងព្រៃ រកស៊ីក្នុងព្រៃ យើងនឹងឲ្យគេនាំទន្សាយ*

ទាំងនោះមក អ្នកត្រូវការទន្សាយបែបណា ( ចូរប្រាប់យើងក្នុងកាលឥឡូវនេះ ) ។

គប្បីជ្រាបសេចក្តីសង្ខេបក្នុងគាថានេះថា

បណ្តាទន្សាយទាំងឡាយ មានទន្សាយធ្វើដោយមាសជាដើម អ្នកប្រាថ្នាទន្សាយណា, ចូរប្រាប់ទន្សាយនោះ, យើងនឹងឲ្យគេធ្វើទន្សាយនោះដល់អ្នក, ឬបើថា អ្នកមិនពេញនឹងទន្សាយនោះទេ, ទន្សាយដែលត្រាច់ទៅក្នុងព្រៃសូម្បីជទែរមែងមាន, យើងនឹងឲ្យគេនាំទន្សាយនោះដល់អ្នក, ម្នាលអ្នកមានមុខស្អាត ចូរប្រាប់មកចុះ អ្នកប្រាថ្នាទន្សាយបែបណា ។

យវបណ្ឌិតស្តាប់ពាក្យរបស់ព្រះរាជាហើយទើបពោលគាថាទី ៦ ថា

ន ចាហមេតេ ឥច្ឆាមិ,
យេ សសា បថវិស្សិតា;

ចន្ទតោ សសមិច្ឆាមិ,
តំ មេ ឱហរ កេសវ។

*ពួកទន្សាយណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំមិនចង់បានទន្សាយនោះទេ ខ្ញុំចង់បានទន្សាយ អំពីដួងព្រះចន្ទ បពិត្រព្រះកេសវៈ សូមព្រះអង្គញុំាងទន្សាយនោះ ឲ្យចុះមក ដើម្បីខ្ញុំ ។*

*ព្រះរាជាស្តាប់ពាក្យរបស់យវបណ្ឌិតហើយ ត្រាស់ថា ប្អូនរបស់យើងឆ្កួតហើយ ដោយមិនមានសង្ស័យឡើយ ដូច្នេះហើយ ទ្រង់ដល់នូវសេចក្តីទោមនស្ស ត្រាស់គាថាទី ៧ ថា*

សោ នូន មធុរំ ញាតិ,
ជីវិតំ វិជហិស្សសិ;
អបត្ថិយំ យោ បត្ថយសិ,
ចន្ទតោ សសមិច្ឆសិ។

*អ្នកណាប្រាថ្នានូវរបស់ ដែលមិនគួរប្រាថ្នា (ដូច ជា) អ្នកប្រាថ្នានូវទន្សាយ អំពីដួងព្រះចន្ទ ម្នាលអ្នកជាញាតិ អ្នកនោះនឹងលះបង់ជីវិត ជាទីស្រឡាញ់ ដោយពិត (ក៏មិនបានទន្សាយនោះដែរ) ។*

គាថានេះមានសេចក្តីអធិប្បាយថា ម្នាលប្អូន អ្នកជាញាតិជាទីស្រឡាញ់របស់យើង អ្នកណាប្រាថ្នានូវរបស់ដែលមិនគប្បីប្រាថ្នា អ្នកនោះនឹងលះបង់ជីវិតរបស់ខ្លួនដែលល្អក្រៃលែង ។

យវបណ្ឌិតស្តាប់ពាក្យព្រះរាជាហើយ ជាអ្នកមិនកម្រើក ពោលថា បពិត្រម្ចាស់បង បងទ្រង់ជ្រាបថា ខ្ញុំប្រាថ្នាទន្សាយអំពីដួងចន្ទ្រ មិនបាន នឹងស្លាប់ ក៏ព្រោះហេតុអ្វី ទើបម្ចាស់បងសោកនឹងបុត្រដែលស្លាប់ទៅហើយនោះ ដូច្នេះហើយ ទើបពោលគាថាទី ៨ ថា

ឯវំ ចេ កណ្ហ ជានាសិ,
យថញ្ញមនុសាសសិ;
កស្មា បុរេ មតំ បុត្តំ,
អជ្ជាបិ មនុសោចសិ។

បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាបយ៉ាងនោះ ព្រះអង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃហេតុអ្វី ព្រះអង្គសោកស្តាយនឹងបុត្រដែលទទួលមរណភាព ក្នុងកាលមុន រហូតមក ក្នុងថ្ងៃនេះ ។

យវបណ្ឌិត ឈរនៅរវាងចន្លោះផ្លូវ ទូលព្រះរាជាយ៉ាងនេះហើយ ពោលថា បពិត្រម្ចាស់បង ខ្ញុំប្រាថ្នានូវរបស់ដែលមានប្រាកដ, ចំណែកព្រះអង្គសោកនឹងរបស់ដែលមិនមានប្រាកដ ដូច្នេះហើយកាលនឹងសម្ដែងធម៌ដល់ព្រះរាជា ទើបពោល ២ គាថាទៀតថា

យំ ន លព្ភា មនុស្សេន,
អមនុស្សេន វា បុន;
ជាតោ មេ មា មរី បុត្តោ,
កុតោ លព្ភា អលព្ភិយំ។

ន មន្តា មូលភេសជ្ជា,
ឱសធេហិ ធនេន វា;
សក្កា អានយិតុំ កណ្ហ,
យំ បេតមនុសោចសិ។

*របស់ណា ដែលមនុស្ស ឬអមនុស្ស មិនគប្បីបានវិញ ដោយប្រាថ្នាថា (ព្រះអង្គប្រាថ្នានូវរបស់នោះថា) បុត្តរបស់អញ កើតហើយកុំស្លាប់ឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ ដែលមិនគប្បីបាន អំពីទីណាកើត ។*

*បពិត្រព្រះកណ្ហាយនគោត្រ ព្រះអង្គសោក ស្តាយនឹងបុត្តណា ដែលទៅកាន់បរលោកហើយ ព្រះ អង្គអាចនាំបុត្តនោះ មកវិញ ដោយមន្ត ដោយថ្នាំ ដែល ធ្វើដោយឫសឈើ ដោយឱសថ ឬក៏ដោយទ្រព្យ មិន បានឡើយ ។*

យវបណ្ឌិតសម្តែងថា មនុស្ស ឬទេវតា មិន គប្បីបានទៀត គឺមិនអាចដើម្បីបានឋានៈណា គឺ សេចក្តីប្រាថ្នាយ៉ាងនេះថា បុត្ររបស់យើងដែលកើត មកហើយ កុំស្លាប់ឡើយ, ព្រះអង្គប្រាថ្នាឋានៈនោះ នឹងគប្បីបានឋានៈដែលមិនគួរបាននោះ គឺឱរសដែល ទៅកាន់បរលោកហើយនោះអំពីណា ? គឺនឹងអាច បានដោយហេតុដូចម្តេច ៗ បានដល់ មិនអាចបាន ឋានៈដែលមិនគួរបាននោះឡើយ ។ អធិប្បាយថា

ព្រោះហេតុនោះ ទើបឈ្មោះថា វត្ថុដែលមិនគួរបាន គឺឋានៈដែលមិនគួរបាននោះ នឹងគប្បីបានអំពីណា ។

ព្រះរាជាវាសុទេពស្តាប់ពាក្យនោះហើយ ត្រាស់ថា នែប្អូន ពាក្យដែលអ្នកពោលមកនេះ គួរពិចារណាមែន, អ្នកបានធ្វើឲ្យយើងដកសេចក្ដីសោកចេញ ដូច្នេះកាលនឹងសរសើរឃដបណ្ឌិត ទើបត្រាស់ ៤ គាថា ថា

យស្ស ឯតាទិសា អស្សុ,
អមច្ចា បុរិសបណ្ឌិតា;
យថា និជ្ឈាបយេ អជ្ជ,
ឃដោ បុរិសបណ្ឌិតោ។

អាទិត្តំ វត មំ សន្តំ,
ឃតសិត្តំវ ចារកំ;

ភរិនា វិយ ឱសិញ្ចំ,
សព្វំ និព្វាបយេ ទរំ។

អព្វហី វត មេ សល្លំ,
យមាសិ ហទយស្សិតំ;
យោ មេ សោកបរេតស្ស,
បុត្តសោកំ អចានុទិ។

សោហំ អព្ពូឡ្ហសល្លោស្មិ,
វីតសោកោ អនាវិលោ;
ន សោចាមិ ន រោទាមិ,
តវ សុត្វាន មាណវ។

*ពួកបុរសជាបណ្ឌិតប្រាកដដូច្នោះ ជាអាមាត្យរបស់ព្រះរាជាណា ដូចយ៉ាងអ្នក ជាបណ្ឌិតបុរសឈ្មោះយជៈ បានពន្យល់ ( ខ្ញុំ ) ក្នុងថ្ងៃនេះ (សោករបស់ព្រះរាជានោះ នឹងមានមកពីណា) ។*

*អ្នកបានស្រោចស្រពនូវយើងដែលក្ដៅ គឺសេចក្ដីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្ដីក្រវល់ក្រវាយទាំងអស់ ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោច នូវភ្លើងកំពុងឆេះឆ្នាំងខ្លាញ់ ។*

*សរ គឺសេចក្ដីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្ដីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះថា បានបន្ទោបង់នូវសេចក្ដីសោកព្រោះបុត្ររបស់យើង ដែលត្រូវសេចក្ដីសោកគ្របសង្កត់ ។*

*ម្នាលមាណព យើងនោះ ជាអ្នកមានសរ គឺសេចក្ដីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីសោក ម្នាលមាណព យើងលែងសោកស្ដាយ លែងយំទួញ ព្រោះបានស្ដាប់នូវពាក្យរបស់អ្នក ។*

បណ្ដាគាថាទាំងនោះ គាថាទី ១ មានសេចក្ដីសង្ខេបថា បុរសជាបណ្ឌិតបែបនេះ ជាអាមាត្យរបស់

ព្រះរាជាណា ព្រះរាជានោះ នឹងមានសេចក្ដីសោក អំពីណា ដូចយ៉ាងយវបណ្ឌិត ញុាំងយើងអ្នកត្រូវសេចក្ដីសោកនឹងបុត្រដែលទៅកាន់បរលោកគ្រប សង្កត់ឲ្យរលត់ គឺឲ្យត្រជាក់ គឺ ឲ្យដឹងច្បាស់ ដើម្បីប្រយោជន៍ដល់ការកម្ចាត់សេចក្ដីសោកនោះ ។ គាថាដ៏សេសមានសេចក្ដីដូចពោលមកនេះឯង ។

ក្នុងអវសាន មានអភិសម្ពុទ្ធគាថាសម្ដែងបញ្ជាក់ថា

ឯវំ ករោន្តិ សប្បញ្ញា,
យេ ហោន្តិ អនុកម្បកា;
និវត្តយន្តិ សោកម្ហា,
យថា ជេដ្ឋំវ ភាតរំ។

ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ ទើបញុាំងជនឲ្យឃ្លាត

ចាកសេចក្តីសោក ដូចឃដបណ្ឌិត ញ៉ាំងព្រះជេដ្ឋា (ឲ្យរួចចាកសេចក្តីសោក) ។

កាលព្រះបាទវាសុទេព ដែលត្រូវឃដកុមារ ធ្វើឲ្យអស់សេចក្តីសោកយ៉ាងនេះហើយទ្រង់គ្រប់គ្រងរាជ្យជាធម្មតា ។ ដោយកាលកន្លងទៅដ៏យូរ បុត្ររបស់ស្តេចជាបងប្អូនទាំង ១០ អង្គ គិតគ្នាថា គេពោលថា កណ្ហទីបាយនៈជាអ្នកមានទិព្វចក្ខុ យើងនឹងសាកល្បងលោកជាដំបូងសិន ។ ទើបប្រដាប់ក្មេងកំលោះមួយរូប សម្តែងដោយអាការៈជាស្ត្រីមានគភ៌ ចងកែវមរកតនឹងពោះ នាំទៅកាន់សម្នាក់ឥសីនោះ ពោលថា បពិត្រលោកម្ចាស់ កុមារិកានេះ នឹងកើតកូនដូចម្តេច? តាបសគិតថា កាលវិនាសរបស់ស្តេចបងប្អូនទាំង ១០ អង្គនេះមកដល់ហើយ, អាយុសង្ខាររបស់យើងនឹងជាយ៉ាងណាហ្ន៎, កាលពិចារណាមើលដឹងថា សេចក្តី

ស្លាប់នឹងមានដល់យើងក្នុងថ្ងៃនេះឯង ដូច្នេះហើយ ពោលថា បពិត្រព្រះកុមារទាំងឡាយ ប្រយោជន៍អ្វី ដោយកុមារនេះ ដល់ព្រះអង្គទាំងឡាយ ។ តាបសត្រូវ ពួករាជកុមារពោលរឿយៗថា បពិត្រលោកម្ចាស់ សូម លោកប្រាប់ដល់ពួកយើង ដូច្នេះហើយ តាបសពោល ថា កុមារនេះនឹងកើតនូវដុំពកគគីរ ក្នុងទី ៧ អំពីថ្ងៃ នេះ, ដោយហេតុនោះ ត្រកូលវាសុទេពនឹងវិនាស, ម្យ៉ាងទៀត បើអ្នកទាំងឡាយកាន់យកដុំគគីរនោះដុត ហើយឆេះបោះចោលក្នុងស្ទឹង ។ លំដាប់នោះ ព្រះ រាជកុមារទាំងនោះពោលនឹងតាបសថា នៃជដិលកោង ឈ្មោះថា បុរសនឹងកើតកូន រមែងមិនមាន ដូច្នេះ ហើយ នាំគ្នាធ្វើនូវកម្មឈ្មោះ **តន្តរជ្ជុក:** (យកខ្សែចង ក) ធ្វើតាបសឲ្យអស់ជីវិតក្នុងទីនេះឯង ។ ព្រះរាជាជា បិតាទាំងឡាយហៅព្រះរាជកុមារ សួរថា ហេតុដូច

*ស្តេច ទើបនាំគ្នាសម្លាប់តាបស, ទ្រង់ស្តាប់រឿងរ៉ាវទាំងអស់ហើយ ភ័យខ្លាច ប្រទានការរក្សាដល់កុមារទាំងនោះ, ក្នុងថ្ងៃទី ៧ ទ្រង់ឲ្យដុំគគីរដែលចេញពីពោះកុមារ ទៅដុត ហើយបោះចោលក្នុងស្ទឹង ។ ផេះគគីរនោះកាលហូរអណ្តែតក្នុងស្ទឹង ទៅជាប់នឹងមាត់ទ្វារនៅកន្លែងមួយ បន្ទាប់មក ក៏កើតជាទៅជាវល្លិ៍ទឹក ។*

*ថ្ងៃមួយ ព្រះរាជាទាំងនោះពោលថា ពួកនឹងលេងនឹង***សមុទ្រកីឡា** *ដូច្នេះទើបទៅកាន់មាត់ទ្វារ ឲ្យគេធ្វើមហាមណ្ឌប សោយ និងផឹកក្នុងអលង្កតមណ្ឌប យកដៃជើងប៉ះពាល់គ្នាដោយការលេង បែកជាពីរចំណែក ធ្វើនូវជម្លោះដ៏ធំ ។ ពេលនោះ ស្តេចមួយអង្គកាលមិនបានអន្ទង់ដទៃ ទៅចាប់យកស្លឹកវល្លិ៍ទឹកមួយអំពីព្រៃវល្លិ៍ទឹកមក ។ ខណៈដែលស្តេចនោះចាប់យកស្លឹកវល្លិ៍ទឹកនោះ ក៏ក្លាយជាអង្រ្រែឈើគគីរ ។*

ស្តេចនោះវាយមហាជនដោយអង្រ្កែគគីរនោះ ។ វត្ថុទាំងអស់ដែលស្តេចទាំងនោះសម្គាល់ថា ជារបស់ដទៃចាប់យកហើយៗ ក៏ក្លាយជាអង្រ្កែគគីរ ។ ស្តេចទាំងនោះប្រហារនូវគ្នានឹងគ្នា ធ្វើឲ្យដល់សេចក្តីវិនាសដ៏ធំ ។ កាលស្តេចទាំងនោះវិនាសធំហើយ ជន ៤ នាក់គឺ ព្រះបាទវាសុទេព ១ ពលទេព ១ បងស្រីអញ្ជនទេវី ១ បុរោហិត ១ នាំគ្នាឡើងរថ រត់ចេញ, ជនដ៏សេសវិនាសហើយទាំងអស់ ។ សូម្បីជនទាំង ៤ នោះ កាលរត់ទៅ ក៏បានដល់ព្រៃកាឡមត្តិកៈ ។ អ្នកចំបាប់មុដ្ឋិកៈធ្វើសេចក្តីប្រាថ្នាកើតជាយក្ស ហើយបានកើតក្នុងព្រៃនោះ ដឹងភាពមកនៃពលទេពហើយ ក៏និម្មិតស្រុកក្នុងព្រៃនោះ ក្លែងភេទជាអ្នកចំបាប់ ត្រាច់ស្រែកគំរាមថា អ្នកណាចង់ប្រយុទ្ធ ។ ពលទេពឃើញយក្សនោះហើយ ពោលថា បពិត្រម្ចាស់បង ខ្ញុំនឹងប្រយុទ្ធជាមួយ

នឹងម្នាក់នោះ ដូច្នេះហើយ កាលវាសុទេពកំពុងហាម នោះឯង ពលទេពក៏ចុះចាករថ ទៅកាន់សម្នាក់យក្ស នោះ ស្រែកគំរាមចូលទៅ ។ លំដាប់នោះ យក្សនោះ ចាប់ដៃពលទេពដែលលាតចេញ យកទៅស៊ី ហាក់ ដូចជា ទំពាស៊ីមើមដំឡូង ។ វាសុទេពដឹងនូវភាពស្លាប់ របស់ពលទេពហើយ កាន់យកបងស្រី និងបុរោហិត ធ្វើដំណើរទៅ អស់រាត្រី កាលព្រះសូរិយារះឡើង ក៏ បានដល់បច្ចន្តគ្រាមមួយ ហើយបង្គាប់បងស្រីនិង បុរោហិតថា ចូរចម្អិនអាហាររួចនាំមក ដូច្នេះហើយ ខ្លួនឯងទៅដេកពួនសម្ងំក្នុងទីកំបាំងក្នុងគុម្ពព្រៃមួយ ។

លំដាប់នោះ ព្រានព្រៃមួយឈ្មោះ **ជរា** ឃើញ គុម្ពឈើកម្រើក សម្គាល់ថា ជ្រូកនៅក្នុងទីនោះ, ទើប គប់លំពែងទៅ ត្រូវជើងវាសុទេព កាលវាសុទេព ពោលថា អ្នកណាចាក់យើង, ជរាព្រានដឹងនូវភាពជា

មនុស្ស គាត់ភ័យខ្លាច ប្រារព្ធនឹងរត់ ។ ព្រះរាជាតាំង សតិ ក្រោកឡើង ត្រាស់ហៅគាត់ថា នែលោកពូ កុំ ខ្លាច ចូរមកណេះ, កាលព្រានមកហើយ ទ្រង់សួរថា លោកឈ្មោះអ្វី ? កាលព្រានពោលថា បពិត្រលោក ម្ចាស់ ខ្ញុំឈ្មោះ ជរា ។ ព្រះរាជាជ្រាបថា បានឮមកថា ពោរាណជនទាំងឡាយព្យាករនូវយើងហើយ ថ្ងៃនេះ យើងនឹងស្លាប់ ដោយឥតសង្ស័យ ដូច្នេះហើយ ទ្រង់ ត្រាស់ថា នែលោកពូ លោកកុំខ្លាចឡើយ ចូរមក រុំ របួសឲ្យយើង, កាលព្រានរុំមុខរបួសហើយ ទ្រង់បញ្ជូន ព្រានឲ្យទៅ ។ វេទនាដ៏មានកម្លាំងបានប្រព្រឹត្តទៅ, កាលបងស្រីនិងបុរោហិតនាំអាហារមក ទ្រង់មិនអាច នឹងសោយបាន ។ ពេលនោះ ទ្រង់ហៅអ្នកទាំងពីរមក ហើយ ត្រាស់ថា ថ្ងៃនេះ យើងនឹងស្លាប់, ចំណែកអ្នក ទាំងឡាយជាសុមុខមាលជាតិ មិនអាចធ្វើកម្មដទៃ

ដើម្បីចិញ្ចឹមជីវិត, ចូរសិក្សានូវវិជ្ជានេះចុះ ដូច្នេះហើយ ទ្រង់ឲ្យសិក្សានូវវិជ្ជាមួយ រួចបញ្ជូនបងស្រីនិង បុរោហិតទៅ ហើយព្រះអង្គអស់ជីវិតក្នុងទីនោះឯង ។ វៀរលែងតែព្រះនាងអញ្ជនទេវីចេញ ស្ដេចទាំងអស់ ដល់នូវសេចក្ដីវិនាសយ៉ាងនេះឯង ។

## ជាតកភាវសាន

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាសឧបាសក បោរាណកបណ្ឌិតទាំងឡាយ ស្ដាប់ពាក្យរបស់បណ្ឌិតទាំងឡាយហើយ បាននាំនូវ សេចក្ដីសោកព្រោះបុត្ររបស់ខ្លួនចេញ, សូមអ្នកគិត ច្រើនឡើយ ដូច្នេះហើយទ្រង់ប្រកាសសច្ចធម៌ ទាំងឡាយ និងប្រជុំជាតក, ពេលចប់សច្ចធម៌ ឧបាសកបានតាំងនៅក្នុងសោតាបត្តិផល ។

- តទា ពេហិណេយ្យោ អានន្ទោ អហោសិ *ពេហិណេយ្យៈក្នុងកាលនោះ បានមកជាអានន្ទ ។*
- វាសុទេវោ សារិបុត្តោ *វាសុទេពបានមកជាសារិបុត្រ ។*
- អវសេសា ពុទ្ធបរិសា *បរិស័ទដ៏សេសបានមកជាពុទ្ធបរិស័ទ ។*
- យវបណ្ឌិតោ បន អហមេវ អហោសិំ *ចំណែកយវបណ្ឌិតគឺ* ***តថាគត*** *នេះឯង ។*

**ចប់ យវបណ្ឌិតជាតក ។**

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទសកនិបាត បិដកលេខ ៥៩ ទំព័រ ២០៥)*



យោ សហស្សំ សហស្សេន,

សង្គាមេ មានុសេ ជិនេ;

ឯកញ្ច ជេយ្យមត្តានំ,

ស វេ សង្គាមជុត្តមោ។

អ្នកណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាម អស់មួយពាន់ៗដង គឺ មួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្ស ខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។